ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ពុទ្ធមណ្ឌលវិបស្សនាធុរៈ
នៃព្រះរាជាណាចក្រកម្ពុជា

# ជីវប្រវត្តិរូបសង្ខេប
# ព្រះធម្មវិបស្សនា សំ ប៊ុនធឿន កេតុធម្មោ
# អតីតអធិបតីពុទ្ធមណ្ឌល និងជាអគ្គនាយកវិបស្សនាធុរៈសិក្សា
# នៃព្រះរាជាណាចក្រកម្ពុជា




**ព្រះធម្មវិបស្សនា សំ ប៊ុនធឿន** ប្រសូត្រនៅថ្ងៃច័ន្ទ ៣ រោច ខែផល្គុន ឆ្នាំរក អដ្ឋស័ក ព.ស.២៤៩៩ ត្រូវនឹងថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៥៧ វេលាម៉ោង ១២:00 នាទីយប់ នៅភូមិរកាកោង ឃុំរកាកោង ស្រុកមុខកំពូល ខេត្តកណ្ដាល ស្ថិតក្នុងត្រកូលកសិករ ។ ញោមប្រុសនាម **ពុយ សំ** បានធ្វើមរណកាលពីឆ្នាំ១៩៩៣ ។ ញោមប្រុសជាសីលវន្ត សមាទានអតិរេកសីល (សីល ១០) រហូតដល់អស់ជន្មាយុ ។

ញោមស្រីនាម **កែវ ស៊ុម** ជាសីលវតី រក្សាសីល ១០ រហូតដល់អស់ជន្មាយុ ។ ព្រះអង្គមានបងប្អូនបង្កើត ៤ នាក់គឺ៖

១. សីលវតី **សំ គង់**

២. លោក **សំ ឈឿន** (ស្លាប់)

៣. ព្រះធម្មវិបស្សនា **សំ ប៊ុនធឿន**

៤. ឧបាសិកា **សំ ចេក**

## ១. អំពីកុមារភាព

កាលពីកុមារ ដោយមានលក្ខណៈសម្បត្តិពីធម្មជាតិ គួបផ្សំ និងការអប់រំ ពីសំណាក់មាតាបិតាផង នោះ កុមារ **សំ ប៊ុនធឿន** គឺជាកុមារមួយរូប ដែលមានអត្តចរិត និងអាកប្បកិរិយាថ្លៃថ្នូរ ទន់ភ្លន់ សុភាពរាបសារ និងចេះជួយទុក្ខធុរៈអ្នកដទៃ ចេះគោរពមាតាបិតា ចាស់ព្រឹទ្ធាចារ្យ គួរជាទីស្រឡាញ់រាប់អាន នៃជនទូទៅ ។

លុះមានវ័យល្មមសិក្សា មាតាបិតាបានបញ្ជូនឲ្យទៅសិក្សារៀនសូត្រលេខនព្វន្ត អក្សរសាស្ត្រ នៅសាលាបឋមសិក្សាវត្តតាំងគោក ស្រុកជើងព្រៃ ខេត្តកំពង់ចាម ដែលជាទឹកដីកំណើតរបស់លោកឪពុក ។ លុះអាយុបាន ៨ ឆ្នាំ កុមារ **សំ ប៊ុនធឿន** បានមកសិក្សានៅសាលាបឋមសិក្សារកាកោងក្រៅ ស្រុកមុខកំពូល ខេត្តកណ្ដាល ខាងទឹកដីកំណើតអ្នកម្ដាយវិញ រហូតដល់ថ្នាក់ទី ៧ ។ អាយុបាន ១០ ឆ្នាំ កុមារ **សំ ប៊ុនធឿន** ឆ្លៀតឱកាសពីការសិក្សា ទូលនំអាកោ និងនំអន្សម ដើរលក់ជាមួយបងស្រី ដើម្បីរកកម្រៃជួយផ្គត់ផ្គង់ជីវភាពក្រុមគ្រួសារ និងជួយដោះបំណុលចាស់ទៀតផង ។ ក្រៅពីនោះ កុមារ **សំ ប៊ុនធឿន** ជួយរែកទឹកស្រោចដំណាំឪពុកម្ដាយ គ្មានពេលទំនេរឡើយ គឺថាពេលព្រឹករែក ៥០ អំរែក និងពេលរសៀល ៥០ អំរែក ព្រមទាំងចេះជួយការងារផ្ទះបាយ ហាក់ដូចជាមនុស្សធំពេញវ័យធម្មតាដែរ ។

នៅអាយុ ១៣ ឆ្នាំ បានប្រឡងជាប់ចូលរៀននៅអនុវិទ្យាល័យសិរីមង្គល ឃុំរកាកោង២ ស្រុកមុខកំពូល ខេត្តកណ្ដាល ។ លុះអាយុ ១៦ ឆ្នាំ យុវជន **សំ ប៊ុនធឿន** ត្រូវឃ្លាតពីឪពុកម្ដាយមករស់នៅទីក្រុងភ្នំពេញ ហើយបានបន្តការសិក្សានៅវិទ្យាល័យពៅអ៊ុម ដល់ថ្នាក់ទី៣ រហូតដល់ព្រឹត្តិការណ៍ ១៧ មេសា ឆ្នាំ១៩៧៥ ។

អាយុ ១៩ ឆ្នាំ នៅក្នុងរបប ៣ ឆ្នាំ ៨ ខែ ២០ ថ្ងៃ នៃបនប្រល័យពូជសាសន៍ យុវជន **សំ ប៊ុនធឿន** ត្រូវបានជម្លាសចេញពីទីក្រុងភ្នំពេញ ដូចប្រជាជនទូទៅដែរ ។ នៅក្នុងរបបនោះ យុវជន **សំ ប៊ុនធឿន** ត្រូវបានគេយកទៅដាក់ឃុំឃាំងឲ្យជាប់គុក ហើយបម្រុងនឹងយកទៅសម្លាប់ ប៉ុន្តែត្រូវបានគេជួយយកអាសា និងដោយមានកុសលផលបុណ្យផងនោះ ក៏ត្រូវបានរួចផុតពីសេចក្ដីស្លាប់ជាលើកទី១ ។ ក្រោយមកទៀត យុវជន **សំ ប៊ុនធឿន** ត្រូវបានគេចាត់ឲ្យនៅក្នុងក្រុមចល័ត ហើយមានជំងឺជាទម្ងន់ រហូតពេទ្យ

យកទៅដាក់ចោលនៅក្នុងបន្ទប់ដាក់សាកសព តែអាយុមិនអស់ក៏បានដឹងស្មារតីឡើងវិញ បានរួចផុតពីសេចក្តីស្លាប់ជាលើកទី២ ។ បន្ទាប់ពីរួចផុតពីសេចក្តីស្លាប់មក យុវជន **សំ ម៉ុនធឿន** ពុំបានរស់នៅជួបជុំគ្រួសារបងប្អូនឡើយ ត្រូវបានគេជម្លាសឲ្យទៅនៅកន្លែងផ្សេងៗគ្នា គ្មានឈប់ឈរ រហូតដល់ឆ្នាំ១៩៧៩ ។ នៅថ្ងៃរំដោះ ៧ មករា ១៩៧៩ យុវជន **សំ ម៉ុនធឿន** បានត្រឡប់មករស់នៅស្រុកកំណើត ហើយបានជួបជុំលោកឪពុកអ្នកម្តាយបងប្អូនវិញ ។ បន្ទាប់ពីបានជួបជុំលោកឪពុកអ្នកម្តាយបងប្អូនមក យុវជន **សំ ម៉ុនធឿន** ក៏បានតាំងចិត្តថា នឹងចូលសាងព្រះផ្នួស បម្រើព្រះពុទ្ធសាសនារហូតអស់មួយជីវិត ដោយមិនគិតកសាងជីវិតអាពាហ៍ពិពាហ៍ និងគ្រួសារឡើយ ។

## ២. អំពីជីវិតផ្នួស និងប្រវត្តិនៃការសិក្សា

ដោយមានសទ្ធាញាណសម្បយុត្ត និងសុឆន្ទៈចំពោះព្រះពុទ្ធសាសនាស្រាប់ផងនោះ ទើបនៅឆ្នាំ១៩៨០ យុវជន **សំ ម៉ុនធឿន** មានអាយុ ២៤ ឆ្នាំ ក៏បានចូលសាងព្រះផ្នួស បួសជាសាមណេរនៅក្នុងពទ្ធសីមាវត្តកែវមុនីជោតិ ស្ថិតនៅក្នុងឃុំរកាកោង ស្រុកមុខកំពូល ខេត្តកណ្តាល ក្នុងសំណាក់ព្រះឧបជ្ឈាយ៍ព្រះនាម **គាំ ពេញ** ។ បន្ទាប់ពីសាងព្រះផ្នួសរួចមក ដោយមានការជួយណែនាំឧបត្ថម្ភ និងការពារពីសប្បុរសជនច្រើនរូប មានលោក **ម៉ី ឃុំ** និងលោកអាចារ្យ **អ៊ុម សារុន** ជាដើម, សាមណេរ **សំ ម៉ុនធឿន** បានខិតខំសិក្សារៀនសូត្រស្វាធ្យាយធម៌អាថ៌សិក្ខាវិន័យ មិនដែលធ្វេសប្រហែសម្តងណាឡើយ ។ រយៈកាលតែ ៧០ ថ្ងៃតែប៉ុណ្ណោះ ព្រះអង្គបានរៀនធម៌សូត្រមន្ត និងធម៌ដារបង្សុកូលចប់សព្វគ្រប់ ថែមទាំងទន្ទេញព្រះបាតិមោក្ខបាលី និងសេចក្តីសម្រាយចេះចាំរត់មាត់ចប់បរិបូណ៌ អាចសម្តែងបានដោយមាត់ទទេយ៉ាងស្ទាត់ជំនាញ ឥតមានទាស់ខុសឡើយ ។

ឆ្នាំ១៩៨១ ព្រះជន្ម ២៥ ព្រះវស្សា បានបំពេញឧបសម្បទាជាភិក្ខុភាវៈ នៅពទ្ធសីមាវត្តឃោសិតារាម ឃុំស្តៅ ស្រុកកងមាស ខេត្តកំពង់ចាម ក្នុងសំណាក់ព្រះឧបជ្ឈាយ៍ព្រះនាម **ជួន សំអ៊ិន** ហើយព្រះឧបជ្ឈាយ៍ ឲ្យនវភិក្ខុនាមបញ្ញត្តិថា **កេតុធម្មោ** ។ បន្ទាប់ពីបំពេញឧបសម្បទាមក ព្រះភិក្ខុ **សំ ម៉ុនធឿន** បានបំពេញការព្យាយាម ក្នុងការសិក្សាកាន់តែទ្វេឡើងថែមទៀត មិនដែលមានកោសជ្ជៈម្តងណាឡើយ ដោយស្របទៅតាមពាក្យចាស់ពោលថា: "**ចួសរៀន**" ។ ហេតុនេះហើយ ទើបព្រះអង្គបាននិមន្តមកគង់នៅវត្តក្តីចាស់ (សុរិយាពោធិ៍មាស) ស្រុកមុខកំពូល ខេត្តកណ្តាល ដើម្បីសិក្សាធម្មវិន័យ ក្នុងសំណាក់លោកអាចារ្យ **មាស ឈិន** រហូតចប់ថ្នាក់ត្រី និងទោ ហើយមានធម្មកោសល្យអាចសម្តែងធម្មទេសនាបានពិរោះក្បោះក្បាយ ជាហេតុធ្វើឲ្យពុទ្ធបរិស័ទ មានការចូលចិត្តគោរពស្រឡាញ់រាប់អានច្រើន ។

លុះឆ្នាំ១៩៨៣ ដល់ ឆ្នាំ១៩៨៥ ព្រះអង្គបាននិមន្តមកគង់ នៅវត្តពាមមង្គល ឃុំរកាកោង ស្រុកមុខកំពូល ខេត្តកណ្តាលវិញ ។ នៅក្នុងវស្សានោះ ព្រះអង្គបានអញ្ជើញលោកគ្រូធម្មាចារ្យ **មាស ឈិន** ដដែល មកបង្រៀនធម្មវិន័យថ្នាក់ឯក ជាបន្តទៀត ។ ដោយវិរិយភាព និងព្រះទ័យជ្រះថ្លាចំពោះការសិក្សា

ព្រះអង្គបានបញ្ចប់ធម្មវិន័យថ្នាក់ឯក ដោយបរិបូណ៌ ព្រមទាំងចេះចាំព្រះអភិធម្មទាំង ៧ គម្ពីរទាំងអត្ថ និងព្យញ្ជនៈ មានសមត្ថភាព និងទេពកោសល្យ កាន់តែចាស់ក្លាថែមទៀត ក្នុងការសម្ដែងធម្មទេសនាគ្រប់ទិសទី ។

ក្នុងរយៈពេលនៃការសិក្សានោះ មានការខ្វះខាតនូវសិក្ខុប្បករណ៍ជាច្រើន សូម្បីតែគម្ពីរដីកាសម្រាប់ស្រាវជ្រាវក៏ពុំមានគ្រប់គ្រាន់ដែរ ។ ពេលនោះ បងស្រីរបស់ព្រះអង្គ ឈ្មោះ **សំ គង់** មានភារៈជួយដោះស្រាយគម្ពីរផ្សេងៗ ប្រគេនព្រះអង្គ ។ ជំនាន់នោះមធ្យោបាយធ្វើដំណើរលំបាកណាស់ បងស្រីរបស់ព្រះអង្គ បានធ្វើដំណើរដោយស្ទើជើង ស្ថិតក្នុងសម្លៀកបំពាក់ខោកុងម៉ូរជើងទទេ ដើរពីរកាកោងទៅភ្នំពេញ ដើម្បីទៅស្រាវជ្រាវរកគម្ពីរនៅកន្លែងនេះបន្តិច កន្លែងនោះបន្តិច បានចំនួន ៥៧ គម្ពីរ (ព្រះត្រៃបិដក) ប៉ុន្តែមិនបានតាមលំដាប់លំដោយ នៃលេខរៀងនោះទេ ។ ក្រោយមកទៀត អាស្រ័យដោយមានការឧបត្ថម្ភពីលោកស្រី **ផល្លា** (បច្ចុប្បន្នធ្វើការនៅក្រសួងធម្មការ និងសាសនា) បានខ្នះខ្នែងជួយខ្ចីគម្ពីរ ដែលខ្វះទាំងប៉ុន្មានពីក្រសួងបាន ១ ក្បាលក្នុង ១ ខែ ។ ដូច្នេះសន្ទុះនៃការសិក្សារបស់ព្រះអង្គ មានភាពឆាប់រហ័សបំផុត គឺព្រះអង្គមានការព្យាយាមសិក្សា រហូតដល់ចប់ ១១០ ក្បាល ។ តាំងពីបព្វជ្ជាជាសាមណេររហូតមក ដោយការសិក្សាព្រះធម៌ដ៏ខ្លាំងផង គួបផ្សំនិងការខ្វះខាតអាហារមិនសូវគ្រប់គ្រាន់ផងនោះ រាងកាយរបស់ព្រះអង្គពុំសូវមានសាច់ឈាមប៉ុន្មានទេ គឺថាតាំងពីបួសមក ព្រះអង្គមិនដែលបានឆាន់នូវចង្ហាន់ត្រីសាច់ឡើយ ឆាន់តែសៀង និងឆៃប៉ូវសម្លបួសអស់ ៦ ព្រះវស្សាគត់ ។

លុះវស្សាទី៧ ព្រះអង្គបានជួបផ្ទាល់ជាមួយ ធម្មាចារ្យ **រស់ ឈុន** ជាឧបាសកម្នាក់ ដែលបង្រៀនវិបស្សនាកម្មដ្ឋាន នៅវត្តពាមមង្គល អាចចេះចាំផ្នែកវិបស្សនាធុរៈ បានល្អប្រពៃ ពុទ្ធបរិស័ទវត្តពាមមង្គលគោរពបូជាជាគ្រូដ៏ប្រពៃក្នុងជំនាន់នោះ ព្រមទាំងជាកល្យាណមិត្តរបស់លោកគ្រូអាចារ្យ **អ៊ុម សារុន** នៅរកាកោងផង ។ នៅសម័យនោះ លោកអាចារ្យ **អ៊ុម សារុន** បានបវរណាព្រះអង្គ ឲ្យរៀនព្រះកម្មដ្ឋានជាមួយលោកគ្រូធម្មាចារ្យ **រស់ ឈុន** តែព្រះភិក្ខុ **សំ ប៊ុនធឿន** កេតុធម្មោ ហាក់ដូចជាមានព្រះទ័យស្ទាក់ស្ទើរ ។

តែដោយមានការព្យាយាមលួងលោងពីសំណាក់ធម្មាចារ្យ **រស់ ឈុន** បានបវរណាថា បើលោកម្ចាស់រៀនធម៌ជាមួយនិងលោកគ្រូ លោកម្ចាស់នឹងបានជាសះស្បើយរោគាពាធជាក់ជាមិនខានឡើយ បើមិនជឿទេ សូមលោកម្ចាស់សាកល្បងតែ ៣ ថ្ងៃសិនក៏បាន ។ វាចារបស់លោកគ្រូ **រស់ ឈុន** ក៏បានធ្វើឲ្យព្រះភិក្ខុ **សំ ប៊ុនធឿន** កេតុធម្មោ សម្រេចព្រះទ័យដាក់ធុរៈថា នឹងសាកល្បងសិក្សាមើលថា តើធម៌ពិត ឬមិនពិត ។ ចាប់តាំងពីបានសាកល្បងមក រយៈកាលតែមួយរាត្រីប៉ុណ្ណោះ ព្រះភិក្ខុ **សំ ប៊ុនធឿន** បានកើតធម៌ភ្លាម អាពាធទាំងឡាយដែលធ្លាប់កើតមានកន្លងមក ដោយខ្វះជីវជាតិនោះ ក៏បានជាសះស្បើយជាបន្តបន្ទាប់ផងដែរ ព្រមទាំងមានការស្ងប់កាយ ស្ងប់ចិត្ត ពេលនេះព្រះអង្គក៏បន្តសិក្សាសមថៈ និងវិបស្សនាកម្ម

ដ្ឋាន ជាមួយលោកគ្រូ **រស់ ឈុន** រហូតដល់ចប់កម្មដ្ឋានទាំង ៤០ ព្រមទាំងឈាន និងសមាបត្តិដោយបរិបូណ៌ ។

ឆ្នាំ១៩៨៥-១៩៩១ គ្រប់ ៧ ឆ្នាំគត់ ដោយសមត្ថភាពរបស់ព្រះអង្គ កាន់តែចាស់ក្លា និងដោយមានការខ្វះខាតព្រះធម្មាចារ្យផងនោះ ទើបពុទ្ធបរិស័ទមានឧទ្ទេសាចារ្យ **អ៊ុម សារុន** ជាដើម បាននិមន្តព្រះភិក្ខុ **សំ ម៉ុនធឿន** ធ្វើជាព្រះធម្មាចារ្យ បង្រៀនព្រះកម្មដ្ឋានដល់ភិក្ខុសាមណេរ ឧបាសក ឧបាសិកា បន្តពីលោកគ្រូតា **រស់ ឈុន** តទៅ ។

ឆ្នាំ១៩៩៤ ដោយមានការណែនាំពីលោក **ម៉ី យុំា** ផង ដោយការចង់ចេះដឹង មិនចេះគ្រប់គ្រាន់ផងនោះ ទើបព្រះអង្គស្វះស្វែងរកសាលាបាលី ដើម្បីសិក្សាបន្តទៀត ។ ពេលនោះ ក៏បានទៅពិភាក្សា និងអង្វរករជាមួយលោកអាចារ្យ **អ៊ុម សារុន** ដើម្បីឲ្យបើកសាលាបាលី ។ ពាក្យអង្វរករនេះ ធ្វើឲ្យរូបលោកអាចារ្យ មានកម្លាំងសទ្ធា ក៏សម្រេចបើកសាលាពុទ្ធិកបឋមសិក្សាមាន ៣ ថ្នាក់ភ្លាម ដែលមានការជួយឧបត្ថម្ភពីពុទ្ធបរិស័ទជិតឆ្ងាយ មានឧបាសិកា **ឆៃ ឡាង** ជាញោមទី២ ជាដើម ។ ពេលនោះ ការសិក្សាមានសមណសិស្ស ៤៥ អង្គ ដែលមានព្រះធម្មាចារ្យ **សំ ម៉ុនធឿន** ជាប្រធាន, ក្នុងការរៀនសូត្រនេះ ព្រះធម្មាចារ្យ **សំ ម៉ុនធឿន** ដើរតួនាទីធ្វើជាសិស្សផង និងធ្វើជាគ្រូធម្មាចារ្យបង្រៀនព្រះវិន័យ និងគោលសាសនសុភាសិត ។ល។ រៀងរាល់ពេលល្ងាច នៅតូបតូចរបស់ព្រះអង្គ មានពន្លឺភ្លើងចង្កៀងផ្លុងៗ នាកណ្តាលរាត្រីកាល ពេលនោះព្រះអង្គកំពុងទន្ទេញមូលវេយ្យាករណ៍ភាសាបាលីរបស់លោកគ្រូ **ឈឹម ស៊ុម** ទាំង ៧ និទ្ទេស ចេះចាំស្ទាត់រត់មាត់ ដូចធម៌សូត្រធម្មតារាល់ថ្ងៃ ឥតមានការភ្លេចភ្លាំងឡើយ ។ បន្ទាប់មកទៀត ព្រះអង្គក៏រៀនសម្ព័ន្ធមាលារបស់លោកគ្រូ **អ៊ុក ជា** ចប់ទៀត ហើយអាចសម្ព័ន្ធបានត្រឹមត្រូវ តាមក្បួនវេយ្យាករណ៍បាលី ឥតមានទាស់ខុសឡើយ ។

លុះដល់ឆ្នាំទី២ ព្រះអង្គបានប្រែគម្ពីរធម្មបទចប់បាន ៤ ភាគ ហើយយករឿងព្រមទាំងសាច់ធម៌មកសម្តែងជូនយាយ តា រៀងរាល់ថ្ងៃឧបោសថទៀតផង ។ ឆ្នាំទី៣ (១៩៩៤) បានប្រែគម្ពីរធម្មបទភាគ ៥ និងភាគ ៨ ចប់ដោយបរិបូណ៌ ទាំងអត្ថ និងព្យញ្ជនៈមិនទើសទាល់ ។ មិនតែប៉ុណ្ណោះ ព្រះអង្គអាចសន្ទនាភាសាបាលីជាមួយប្រទេស ដែលនិយាយភាសាបាលីបានខ្លះផង ។

ដោយខ្វះមធ្យោបាយ នឹងបង្រៀនគម្ពីរធំៗ ប្រគេនព្រះអង្គបន្តទៀតបានដូចជា៖ មង្គលត្ថទីបនី វិសុទ្ធិមគ្គ និងគម្ពីរផ្សេងៗ ទើបឧទ្ទេសាចារ្យ **អ៊ុម សារុន** ក៏សម្រេចបវរណាព្រះធម្មាចារ្យ **សំ ម៉ុនធឿន** ឲ្យព្រះអង្គនិមន្តទៅបន្តការសិក្សាព្រះបរិយត្តិធម៌ថ្នាក់មធ្យម ជាមួយលោកគ្រូឧទ្ទេសាចារ្យនាម **ជឹម ឡុញ** (ហៅ **ថន**) នៅវត្តសុវណ្ណវតី ឃុំព្រែកតាម៉ាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ជាបន្តទៀត និងបង្រៀនវិបស្សនាធុរៈផង ។ បន្ទាប់ពីប្រែគម្ពីរខាងលើនេះ នៅពាក់កណ្តាលឆ្នាំ១៩៩៥ សម្តេចព្រះសង្ឃរាជទ្រង់ព្រះនាម **ទេព វង្ស** ជាមួយនឹងលោក **ម៉ី យុំា** ជាទីប្រឹក្សារបស់សម្តេច ទ្រង់បានពិគ្រោះពិភាក្សារិះរកមធ្យោ

បាយយ៉ាងណា ឲ្យព្រះពុទ្ធសាសនាដែលរស់ឡើងវិញនេះ បានជ្រួតជ្រាបដល់ពុទ្ធបរិស័ទទូទៅ ដើម្បីគោរព ប្រតិបត្តិឲ្យបានទូលំទូលាយរីកចម្រើនទៅថ្ងៃអនាគតវែងឆ្ងាយ ។ល។ ព្រះអង្គទ្រង់មានព្រះតម្រិះចង់ឲ្យ ពុទ្ធបរិស័ទទាំងបព្វជិត និងគ្រហស្ថ បានសិក្សាស្វែងយល់ និងគោរពប្រតិបត្តិគ្រប់ៗគ្នា ។ សម្តេចទ្រង់ លើកឡើងធុរៈក្នុងព្រះពុទ្ធសាសនាទាំងពីរគឺៈ **គន្ថធុរៈ និងវិបស្សនាធុរៈ** ថា គន្ថធុរៈយើងបានរៀបចំជាផ្លូវ ការឡើងវិញហើយ ក៏គួរយកចិត្តទុកដាក់រៀបចំខាងផ្នែកវិបស្សនាធុរៈជាផ្លូវការផងដែរ ដើម្បីអនុគ្រោះដល់ ភិក្ខុ សាមណេរ ឧបាសក និងឧបាសិកា ពុទ្ធបរិស័ទបានសិក្សាប្រតិបត្តិ ។ល។ ព្រះអង្គក៏សព្វព្រះរាជហ ឫទ័យដាក់បញ្ហានេះក្នុងអនុសំវច្ឆរមហាសន្និបាត លើកទី៥ ឆ្នាំ១៩៩៥ ដើម្បីពិភាក្សា និងអនុមតិ ដែលអនុ សំវច្ឆរមហាសន្និបាត មានព្រះមន្ត្រីសង្ឃគ្រប់ឋានានុក្រម មន្ត្រីក្រោមឱវាទក្រសួងធម្មការ និងសាសនា យាង និមន្ត អញ្ជើញចូលរួម បានសម្រេចជាឯកច្ឆ័ន្ទ បើកវិបស្សនាធុរៈសិក្សាជាផ្លូវការតទៅ ។

បន្ទាប់ពីអនុសំវច្ឆរមហាសន្និបាតចប់ហើយ សម្តេចព្រះសង្ឃរាជជាអម្ចាស់ ទ្រង់ត្រាស់ឲ្យលោក **ម៉ី ឃុំ** ស្រាវជ្រាវទូទាំងប្រទេស ជ្រើសរើសយកព្រះធម្មាចារ្យផ្នែកវិបស្សនាធុរៈ ដើម្បីរៀបចំជាផ្លូវការ ឲ្យសម ស្របតាមការវិវឌ្ឍរីកចម្រើន នៃព្រះពុទ្ធសាសនាយើង ។ ក្នុងការស្រាវជ្រាវនេះ ក៏បានឃើញថា ក្រុមព្រះធ ម្មាចារ្យ **សំ ប៊ុនធឿន** បានសិក្សាវិបស្សនាធុរៈ តាមគម្ពីរវិសុទ្ធិមគ្គ ដែលមានព្រះត្រៃបិដកជាគោល តាំងពី លោកគ្រូធម្មាចារ្យ **រស់ ឈុន** ជាគ្រូរបស់ព្រះអង្គមក ។ អាស្រ័យហេតុនេះ ទើបសម្តេចជាអម្ចាស់ទ្រង់សព្វ ព្រះរាជហឫទ័យ យាងទៅកាន់វត្តសុវណ្ណវតី ឃុំព្រែកតាម៉ាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ជាទី កន្លែងដែលព្រះធម្មាចារ្យ **សំ ប៊ុនធឿន** គង់នៅដោយផ្ទាល់ព្រះអង្គ ដើម្បីជួបពិភាក្សាការងារនេះ ជាមួយ ព្រះអង្គ និងព្រះឧទ្ទេសាចារ្យ **ខឹម ឡុញ** (ហៅ **ថន**) ផ្ទាល់ ។

ដោយពេលនោះ កំពុងបើកវគ្គសិក្សា ព្រះធម្មាចារ្យ **សំ ប៊ុនធឿន** ជាប់ភារកិច្ចបង្រៀន ក៏សូម និមន្តព្រះឧទ្ទេសាចារ្យ **ខឹម ឡុញ** (ហៅ **ថន** ) ទៅគង់នៅវត្តឧណ្ណាលោមមុន ដើម្បីគង់នៅជិតសម្តេចជា អម្ចាស់ ងាយស្រួលពិភាក្សាការងារនេះ និងស្នើសុំឲ្យព្រះអង្គបង្រៀនបាលី ក្នុងសាលាពុទ្ធិកបឋមសិក្សាវត្ត ឧណ្ណាលោមផង ។

លុះកន្លងមកចំនួន ៣ ខែ (ដើមឆ្នាំ១៩៩៦) ចប់ការបង្រៀននៅវត្តសុវណ្ណវតីហើយ ព្រះធម្មាចារ្យ **សំ ប៊ុនធឿន** ក៏ត្រូវនិមន្តទៅគង់នៅឯទីក្រុងភ្នំពេញដែរ ប៉ុន្តែព្រះអង្គ សំណូមពរសូមគង់នៅវត្តណាមួយ ជាយក្រុងភ្នំពេញ ដែលមានសភាពស្ងប់ស្ងាត់បង្គួរ ។ សម្តេចព្រះសង្ឃរាជជាអម្ចាស់ ក៏បានទ្រង់ត្រាស់ឲ្យ អញ្ជើញលោក **ជា សុធីរ៍** ប្រធានគណៈកម្មការវត្តនន្ទមុនី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានី ភ្នំពេញ ចូរទៅគាល់ព្រះអង្គ ដើម្បីស្នើសុំឲ្យរៀបចំវត្តនេះ ប្រគេនព្រះធម្មចារ្យ **សំ ប៊ុនធឿន** គង់នៅហើយ យកវត្តនេះជាទីស្នាក់ការមជ្ឈមណ្ឌលវិបស្សនាធុរៈសិក្សាទូទាំងប្រទេសតែម្តង ដែលមានព្រះធម្មចារ្យ **សំ ប៊ុនធឿន** ជាអធិបតី ។

បន្ទាប់ពីបានឮសម្តេចជាអម្ចាស់ដាក់បន្ទុកការងារនេះភ្លាម លោក **ជា សុធីរ៍** ហាក់ដូចជាភ្ញាក់លាន់មាត់ថា៖ ឱហ្ន៎ ! ពេលនេះ សម្តេចជាអម្ចាស់ ប្រទានវត្ថុដ៏មានតម្លៃ ថ្លៃលើសមាសពេជ្ររាប់លានដងទៅទៀត ទូលព្រះបង្គំរំភើបណាស់ រំភើបអ្វីម្លេះទេ ទូលព្រះបង្គំសូមទទួលអំណរសាទរយ៉ាងក្រៃលែង ។ល។ បន្ទាប់មកលោក **ជា សុធីរ៍** បាននិមន្តព្រះសង្ឃ គណៈកម្មការវត្ត មកប្រជុំរៀបចំព្រមព្រៀងគ្នាជាឯកច្ឆ័ន្ទទទួលយកដោយក្តីជ្រះថ្លា ហើយក៏បានរៀបចំវត្ត ធ្វើកុដិ ប្រគេនព្រះអង្គនិមន្តគង់នៅយ៉ាងសមរម្យ ។

ឆ្នាំ១៩៩៥ (រយៈពេលដែលព្រះធម្មចារ្យ **សំ ប៊ុនធឿន** គង់នៅវត្តសុវណ្ណវតី) មានសប្បុរសម្នាក់នាម **ស្រី ជាសាធារណ៍** និងលោកស្រី **ហ៊ុយ សារី** មានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា បានវេរប្រគេនដីមួយកន្លែង ដែលស្ថិតនៅខាងលិចជើងភ្នំព្រះរាជទ្រព្យ ភូមិភ្នំ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល ដល់ព្រះសង្ឃ មានសម្តេចព្រះសង្ឃរាជ **ទេព វង្ស** និងព្រះធម្មចារ្យ **សំ ប៊ុនធឿន** ជាប្រធាន សូមឲ្យព្រះអង្គព្រះមេត្តាទទួលទុកជាសម្បត្តិព្រះពុទ្ធសាសនាតរៀងទៅ ។ នៅពេលទទួលរួចហើយ សម្តេចជាអម្ចាស់ទ្រង់ប្រសិទ្ធិនាមជាដំបូងថា៖ **"អាស្រមសន្តិវ័ន្ត"** ក្រោយមកអាស្រមនេះ ជាសាខាមជ្ឈមណ្ឌលវិបស្សនាធុរៈវត្តនន្ទមុនី ដោយបាននិមន្ត ព្រះភិក្ខុ សាមណេរ ឧបាសក និងឧបាសិកា មានព្រះភិក្ខុ **ស្រី ជា សុមេធ** និងសីលវតី **ស្រីព្រហ្មចារិនី** ជាដើម ឲ្យគង់ស្នាក់នៅគ្រប់គ្រង នឹងដឹកនាំបដិបត្តិ ព្រះធម៌វិបស្សនាកម្មដ្ឋាន នៅទីនេះ ។

ឆ្នាំ២០០០ មជ្ឈមណ្ឌលវិបស្សនាធុរៈវត្តនន្ទមុនី ក៏ត្រូវបានប្រកាសតែងតាំង ជាពុទ្ធមណ្ឌលវិបស្សនាធុរៈ **តាមប្រកាសលេខ ៨៦/២០០០ ក.ស.វ.វ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០០** ដែលមានព្រះធម្មវិបស្សនា **សំ ប៊ុនធឿន** កេតុធម្មោ ជាអធិបតី និងជាអគ្គនាយកវិបស្សនាធុរៈសិក្សា នៃព្រះរាជាណាចក្រកម្ពុជា ។

ការរីកចម្រើនលើការផ្សព្វផ្សាយព្រះធម៌ មានទំហំធំធេញ ដែលសភាពការណ៍ជាក់ស្តែង នៅវត្តនន្ទមុនី មិនអាចទទួលសិស្សគង់ស្នាក់នៅ តាមសំណូមពរ អាស្រ័យហេតុនេះ ធម្មវិបស្សនា **សំ ប៊ុនធឿន** ក៏បានថ្វាយយោបល់ និងទទួលព្រះរាជានុញ្ញាតពីសម្តេចជាអម្ចាស់ផ្លាស់ប្តូរទីតាំងពីវត្តនន្ទមុនី មកអាស្រមសន្តិវ័ន្ត **នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០០** ហើយបានប្តូរនាមពីអាស្រមសន្តិវ័ន្តមកជាពុទ្ធមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា រហូតមកដល់បច្ចុប្បន្ននេះ ។

បន្ទាប់ពីនិមន្តមកគង់នៅទីនេះ ព្រះអង្គពុំសូវមានពេលទំនេរឡើយ ពីមួយថ្ងៃទៅមួយថ្ងៃ មានការងារជាច្រើនដែលត្រូវបំពេញរាល់ថ្ងៃ ដូចជា រៀបចំផ្សព្វផ្សាយព្រះធម៌វិន័យផ្នែកវិបស្សនាធុរៈ ចងក្រងនិងនិពន្ធតែងសៀវភៅធម៌ សម្តែងព្រះធម៌ និងរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនៅទីនេះ ។ល។ ទោះបីការងារមានទំហំធំធេញយ៉ាងណាក៏ដោយ ក៏ព្រះអង្គពុំដែលមានការត្អូញត្អែរម្តងណាឡើយ ។ មួយវិញទៀត ព្រះអង្គជាព្រះសង្ឃមួយរូប ដែលមានវិរិយភាពដ៏ខ្លាំងក្លាបំផុត ចំពោះវិស័យអប់រំផ្នែកព្រះពុទ្ធសាសនា ជា

ពិសេសគឺការសិក្សារៀនសូត្រផ្ទាល់ ព្រះអង្គនេះតែម្តង ។ ដូច្នេះហើយជានៅ**ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០០** ព្រះអង្គបាននិមន្តទៅបន្តការសិក្សានៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជជាបន្តទៀត ក្នុងការសិក្សានៅពុទ្ធិកសាកលវិទ្យាល័យនេះ មានមុខវិជ្ជាជាច្រើនដែលត្រូវសិក្សារៀនសូត្រដូចជា៖ សង្គមវិជ្ជា (Sociology) ច្បាប់ (Law), នរវិទ្យា (Anthropology), វិទ្យាសាស្ត្រអប់រំ (Educational Science), តក្កវិទ្យា (Logic and Critical Thinking), និង ទស្សនវិជ្ជា (Philosophy), ជាដើម ប៉ុន្តែមុខវិជ្ជាដែលព្រះអង្គពេញចិត្តនោះគឺ ទស្សនវិជ្ជាព្រះពុទ្ធសាសនា (Buddhist Philosophy) ។

## ៣. អំពីស្នាព្រះហស្តសមិទ្ធិផលនានា

ទន្ទឹងនឹងការងាររៀនសូត្រ និងការអប់រំបង្រៀនធម៌ដល់ពុទ្ធបរិស័ទ ព្រះអង្គបានដឹកនាំកសាង នូវថាវរវត្ថុផ្សេងៗ ដើម្បីទុកជាឧត្តមប្រយោជន៍ជាតិ និងសាសនា ដូច្នេះសមិទ្ធិផលទាំងឡាយ ដែលជាស្នាព្រះហស្ត ដឹកនាំកសាងរួមមាន៖

- **វត្តពាមខ្ទល** ៖ បានដឹកនាំក្រាលការ៉ូកសាង បល្ល័ង្គ និងព្រះពុទ្ធបដិមា ថែមទាំងកសាងសាលាបឋមសិក្សារកាកោងក្រៅបានបីខ្នង ទិញតុ និងកៅអី ឆ្នាំ១៩៨៣ ។
- **វត្តសុវណ្ណាវតី** ៖ កសាងស្រះទឹក កុដិថ្ម និងចាក់ដីបំពេញទីធ្លាវត្តថែមទៀត ។
- **វត្តនន្ទមុនី** ៖ ដឹកនាំកសាងសមិទ្ធិផលមានដូចជា៖
  - សាងសងឃឿនព្រះវិហារ (លោក ស្រី **ជាសាធារណ៍** និងលោកស្រី **ហ៊ុយ សារី**)
  - កុដិឈើ ១ ខ្នង (លោក **ជា សារ៉ាត** និងអ្នកស្រី **តែ មានីរ៉ុង** និងពុទ្ធបរិស័ទ)
  - អគារថែវ ២ ខ្នង មាន ១០ បន្ទប់ កសាងដោយពុទ្ធបរិស័ទ ១ ខ្នង និងព្រឹទ្ធាចារ្យ **រស់ ឡុម** ១ ខ្នង
  - អគារសិក្សា ២ ខ្នង កសាងដោយសីលវន្ត **រស់ ឈុន**
  - អគារសមាធិ ១ ជាន់ រួមជាមួយនឹងពុទ្ធបរិស័ទ មានលោក **ង៉ែត ផេង** និងភរិយា ព្រមទាំងបុត្រ ជាដើម
  - អាងទឹក ៦០ ម៉ែត្រគីប X ២០ ម៉ែត្រគីប
- **ពុទ្ធមណ្ឌលវិបស្សនាធុរៈ** ៖ បានដឹកនាំកសាងសមិទ្ធិផលរួមមាន៖
  - ជីកស្រះទឹកមានបណ្តោយ ៨០ ម៉ែត្រ និងទទឹង ៦០ ម៉ែត្រ
  - កសាងព្រះវិហារបាន ៥០ % កសាងឆ្នាំ១៩៩៨
  - កសាងសាលាធម្មសភា ឆ្នាំ១៩៩៩
  - ម៉ាស៊ីនភ្លើងមួយគ្រឿង ដែលមានកម្លាំង ៥០ គីឡូវ៉ាត់ ទិញឆ្នាំ១៩៩៩
  - កសាងផ្ទះបាយ និងឃ្លាំងដាក់សម្ភារៈប្រើប្រាស់ ឆ្នាំ២០០០

- ពង្រីកផ្ទៃដីពុទ្ធមណ្ឌលវិបស្សនាធុរៈពី ៦ ហិកតា ដល់ ១៥ ហិកតា ឆ្នាំ១៩៩៦-២០០០
- ចាក់ដីបំពេញរណ្ដៅកុដិ ៤ ហិកតាកន្លះ ឆ្នាំ១៩៩៨-២០០០
- កសាងមហាកុដិ ២ ជាន់ ឆ្នាំ២០០០
- ឧបដ្ឋានសាលា ឆ្នាំ២០០០
- កុដិថ្ម ១ ខ្នង មាន ២ ជាន់ ៤ បន្ទប់ ដោយថវិកាព្រះអង្គផ្ទាល់
- តូបស្លឹក ៣៥០ ខ្នង ឆ្នាំ២០០០-២០០១
- ធ្វើផ្លូវថ្មល់ក្នុង និងក្រៅពុទ្ធមណ្ឌលវិបស្សនាធុរៈ ឆ្នាំ២០០០-២០០១
- កសាងអាងទឹកចំណុះ ១០០០ ម៉ែត្រគីប និង ៥០០ ម៉ែត្រគីប ព្រមទាំងបណ្ដាញទឹកភ្លើង ឆ្នាំ២០០២
- កសាងខ្លោងទ្វារ អង្គរធំ-បន្ទាយស្រី ឆ្នាំ២០០០-២០០១
- បន្ទប់អនាម័យ ២០ ខ្នង (ក្នុង២០ ខ្នងមាន ៥ បន្ទប់) ឆ្នាំ២០០១
- ដងទង់ ១ គូ កសាងឆ្នាំ២០០១
- ព្រះពុទ្ធបដិមាមុជ្ជលិន្ទ កសាងឆ្នាំ១៩៩៩-២០០០
- បណ្ណាល័យកសាង ឆ្នាំ២០០២
- សាលាអប់រំ កសាងឆ្នាំ២០០២
- កុដិទទួលភ្ញៀវ កសាងឆ្នាំ២០០២
- កសាងអាគារដាក់ម៉ាស៊ីនភ្លើងធំ ២៥០ គីឡូវ៉ាត់
- កសាងសាលាអប់រំវិបស្សនាធុរៈ សម្រាប់សីលវន្ត និងសីលវតី ឆ្នាំ២០០២ ។

## ៤. ការងារបណ្ដុះបណ្ដាល និងអប់រំ

ដើម្បីបណ្ដុះបណ្ដាលសិស្ស និងអប់រំឲ្យទទួលបាននូវគុណភាពខ្ពស់ និងមានលទ្ធផលល្អនោះ ព្រះអង្គបានរៀបចំនូវគោលការណ៍ដូចខាងក្រោមៈ

### ១. ការចងក្រង និពន្ធសៀវភៅ

ព្រះអង្គបានរៀបរៀង និងចងក្រងសៀវភៅ ហើយផ្សព្វផ្សាយដល់ពុទ្ធបរិស័ទសម្រាប់សិក្សាដូចខាងក្រោម ៖

- សៀវភៅសមថ និងវិបស្សនាកម្មដ្ឋាន
- សៀវសីលកថាសង្ខេប
- គោលធម៌ថ្នាក់បឋម
- គោលធម៌ថ្នាក់មធ្យម

- ❖ គោលធម៌ថ្នាក់ឧត្តម
- ❖ សៀវភៅបឋមវិបស្សនា ពិស្តារ
- ❖ សៀវភៅគិរីមានន្ទសូត្រ
- ❖ សៀវភៅបាដិហារិយបោសថ
- ❖ សៀវភៅនិយមសីល
- ❖ សៀវភៅវិក្រិត្យការគរុកោសល្យ
- ❖ សៀវភៅមនុស្សចង់បានអ្វី
- ❖ សៀវភៅធុតង្គ និងបរិវាស
- ❖ សៀវភៅមធ្យមវិបស្សនាពិស្តារ
- ❖ សៀវភៅវិន័យសីល ១០
- ❖ សៀវភៅឧត្តមវិបស្សនា ឆ្នាំទី១ ឆ្នាំទី២

### ២. ការងារបណ្តុះបណ្តាល

ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ពុទ្ធបរិស័ទទូទាំងប្រទេស ដែលខ្វះខាតគ្រូវិបស្សនាកម្មដ្ឋាន ព្រះអង្គបានរៀបចំបណ្តុះបណ្តាលគ្រូបង្គោល និងសិក្ខាកាម ដែលទទួលបានវិញ្ញាបនបត្រ មានចំនួន ២៤១០ អង្គ/នាក់ ក្នុងនោះមាន៖

- ថ្នាក់ឧត្តមមានចំនួន ១១ អង្គ/នាក់
- ថ្នាក់មធ្យមមានចំនួន ៦១ អង្គ/នាក់
- ថ្នាក់បឋមមានចំនួន ២៣៣៨ អង្គ/នាក់ ។

### ៣. ការបង្កើតមជ្ឈមណ្ឌលវិបស្សនាធុរៈ និងការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងតាមរាជធានី/ខេត្ត មានដូចជា៖

| | | | |
|---|---|---|---|
| - មជ្ឈមណ្ឌលវិបស្សនាធុរៈខេត្តក្រចេះ | ថ្ងៃទី២៦ | ខែមករា | ឆ្នាំ១៩៩៩ |
| - មជ្ឈមណ្ឌលវិបស្សនាធុរៈខេត្តតាកែវ | ថ្ងៃទី១០ | ខែកុម្ភៈ | ឆ្នាំ១៩៩៩ |
| - មជ្ឈមណ្ឌលវិបស្សនាធុរៈខេត្តកែប | ថ្ងៃទី១៨ | ខែកុម្ភៈ | ឆ្នាំ១៩៩៩ |
| - មជ្ឈមណ្ឌលវិបស្សនាធុរៈខេត្តសៀមរាប | ថ្ងៃទី២៣ | ខែកក្កដា | ឆ្នាំ១៩៩៩ |
| - មជ្ឈមណ្ឌលវិបស្សនាធុរៈខេត្តពោធិ៍សាត់ | ថ្ងៃទី២០ | ខែឧសភា | ឆ្នាំ២០០០ |
| - មជ្ឈមណ្ឌលវិបស្សនាធុរៈខេត្តកំពង់ធំ | ថ្ងៃទី៣១ | ខែសីហា | ឆ្នាំ២០០០ |
| - មជ្ឈមណ្ឌលវិបស្សនាធុរៈខេត្តព្រះសីហនុ | ថ្ងៃទី០៩ | ខែកញ្ញា | ឆ្នាំ២០០០ |
| - មជ្ឈមណ្ឌលវិបស្សនាធុរៈរាជធានីភ្នំពេញ | ថ្ងៃទី២២ | ខែតុលា | ឆ្នាំ២០០០ |

- មជ្ឈមណ្ឌលវិបស្សនាធុរៈខេត្តកំពង់ឆ្នាំង ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០០
- មជ្ឈមណ្ឌលវិបស្សនាធុរៈខេត្តស្វាយរៀង ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០១
- មជ្ឈមណ្ឌលវិបស្សនាធុរៈខេត្តកំពត ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០២
- មជ្ឈមណ្ឌលវិបស្សនាធុរៈខេត្តព្រៃវែង ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០០
- មជ្ឈមណ្ឌលវិបស្សនាធុរៈខេត្តមណ្ឌលគិរី ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០២

### ៤. ការបង្កើតគណៈកម្មាធិការនាយក ដឹកនាំសិក្សាបាន៤រាជធានី/ខេត្តៈ

- រាជធានីភ្នំពេញ វត្តនន្ទមុនី
- ខេត្តពោធិ៍សាត់
- ខេត្តស្វាយរៀង
- ខេត្តតាកែវ

ក្រៅពីការផ្សព្វផ្សាយតាមរយៈសៀវភៅ និងការបង្កើតឲ្យមានមជ្ឈមណ្ឌលវិបស្សនាធុរៈ សរុបទាំងអស់មាន ១៧ រាជធានី/ខេត្ត ដែលមានសិក្ខាកាមប្រតិបត្តិវិបស្សនាធុរៈប្រមាណជាង ៣០,០០០ អង្គ/នាក់ ព្រះអង្គបានផ្សព្វផ្សាយតាមរយៈវិទ្យុ ដែលមានពុទ្ធបរិស័ទស្តាប់ស្ទើរតែពេញផ្ទៃប្រទេសទៀតផង ។

### ៤. អំពីសមណស័ក្តិ

នៅឆ្នាំ១៩៩៦ ត្រូវបានសម្តេចព្រះមហាសុមេធាធិបតី **ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា តែងតាំងជាអធិបតីមជ្ឈមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា ដែលមានទីស្នាក់ការនៅវត្តនន្ទមុនី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

នៅថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៩៧ ព្រះអង្គត្រូវបានព្រះបាទសម្តេច **ព្រះនរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់សព្វព្រះរាជហឫទ័យប្រោសប្រទានតែងតាំងជា **ព្រះធម្មវិបស្សនា** ព្រះរាជាគណៈថ្នាក់ចត្វា គណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា ។

នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០០ ត្រូវបានតែងតាំងជាអធិបតីពុទ្ធមណ្ឌល និងជាអគ្គនាយកវិបស្សនាធុរៈសិក្សា នៃព្រះរាជាណាចក្រកម្ពុជា ។

នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០១ ត្រូវបានតែងតាំងជាព្រះឧបជ្ឈាយ៍ បំបួសកុលបុត្រ ។

ព្រះធម្មវិបស្សនា **សំ ប៊ុនធឿន** កេតុធម្មោ អធិបតីពុទ្ធមណ្ឌល និងជាអគ្គនាយកវិបស្សនាធុរៈសិក្សា នៃព្រះរាជាណាចក្រកម្ពុជា តាំងពីព្រះអង្គបព្វជ្ជា រហូតទទួលបានគោរមងារខ្ពង់ខ្ពស់ពេលនេះ ដោយវិរិយភាពរបស់ព្រះអង្គ និងការបំពេញតួនាទីជាវិរសមណសង្ឃ ធ្វើឲ្យពុទ្ធបរិស័ទគោរព ប្រតិបត្តិ ស្រឡាញ់ រាប់អានក្នុងមនោសញ្ចេតនាជ្រះថ្លា ពោលគឺព្រះអង្គបានចូលរួមយ៉ាងសកម្មក្នុងការដឹកនាំមហាជនឲ្យធ្វើសេចក្តីល្អសម្រាប់ខ្លួនឯង និងសង្គមជាតិ លះបង់នូវលោភៈ ទោសៈ និងមោហៈ ព្រមទាំងធ្វើឲ្យបញ្ញាជាក់

ច្បាស់ក្នុងសង្ខារធម៌ទៀតផង ។ ពីមួយថ្ងៃទៅមួយថ្ងៃ តាំងពីព្រលឹមទល់ព្រលប់ ព្រះអង្គមិនដែលមានពេលសម្រាកឡើយ ព្រះអង្គបានដើរតួនាទីជាអ្នកស្ថាបនាសង្គម តាមរយៈការផ្សព្វផ្សាយព្រះធម៌វិន័យ ដល់ពុទ្ធបរិស័ទស្ទើរតែគ្រប់ទីកន្លែងទាំងអស់ ដោយព្រះទ័យជ្រះថ្លាជាទីបំផុត ។ ប៉ុន្តែជា**អកុសល នៅថ្ងៃ ៦ កើត ខែមាឃ ឆ្នាំមមែ ចត្វាស័ក ព.ស.២៥៤៦ ត្រូវនឹងថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៣ វេលាម៉ោង ១:១១ នាទីយប់ ព្រះអង្គក៏បានអនិច្ចធម្ម ក្នុងព្រះជន្មាយុ ៤៧ ព្រះវស្សា ដោយកម្មក្ខយមរណៈ** ធ្វើឲ្យពុទ្ធបរិស័ទ សិស្សគណ គ្រប់មជ្ឈដ្ឋានទូទាំងប្រទេស មានក្តីតក់ស្លុតរន្ធត់អួលអាក់ រកអ្វីប្រៀបផ្ទឹមពុំបានឡើយ ។

**សម្តេច ព្រះរាជាគណៈ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា អស់លោក លោកស្រី ឧបាសក ឧបាសិកា និងពុទ្ធបរិស័ទគ្រប់រូប ជាទីគោរពសក្ការៈ និងរាប់អាន !**

យោងតាមសកម្មភាពរបស់**ព្រះធម្មវិបស្សនា សំ ប៊ុនធឿន កេតុធម្មោ** តាំងពីប្រសូត្រ រហូតមកដល់ពេលអនិច្ចធម្មនេះ បញ្ជាក់ថាព្រះអង្គគឺជាវរសមណសង្ឃ និងជាខេមរបុត្រដ៏ឆ្នើម ដែលមួយជីវិតរបស់ព្រះអង្គ បានលះបង់នូវព្រះកាយពល និងព្រះបញ្ញាញាណ ដើម្បីបុព្វហេតុជាតិ និងសាសនា គ្មានស្តាយស្រណោះឡើយ ។ តែអនិច្ចា ព្រះអង្គបានទទួលអនិច្ចធម្មដោយ **អកាលមរណៈ** ធ្វើឲ្យខ្ញុំព្រះករុណាយើងខ្ញុំទាំងអស់គ្នា មានសេចក្តីទុក្ខក្រៀមក្រំ ស្រងូតស្រងាត់ជាទីបំផុត ។ ពីមុនមកយើងទាំងអស់គ្នា បានបំពេញកុសលនៅទីនេះ ធ្លាប់មានសោមនស្សរីករាយ ដោយបានជួបព្រះភ័ក្ត្រ ព្រះកាយវិការដ៏រស់រវើករបស់ព្រះអង្គ ប៉ុន្តែពេលនេះ ភាពរីករាយដែលធ្លាប់មានពីអតីតកាល ប្រែក្លាយជាមានទឹកមុខស្រពាប់ស្រពោន ស្រយុតស្រយង់ ក្រៀមក្រំ ខ្លោចផ្សានៅក្នុងអារម្មណ៍ទៅវិញ ។

**អធុវំ មេ ជីវិតំ ធុវំ មេ មរណំ** ជីវិតរបស់មនុស្សទាំងឡាយមិនទៀង តែសេចក្តីស្លាប់របស់មនុស្សទៀង ក៏ពិតមែនហើយ តែយើងទាំងអស់គ្នា នៅមិនទាន់អស់ចិត្តនៅឡើយ ព្រោះមនោសញ្ចេតនា និងអារម្មណ៍របស់យើងទាំងអស់គ្នាជាសិស្សគណ បាននឹងកំពុងជិតជាប់នូវព្រះកាយវិការ និងសកម្មភាពគ្រប់បែបយ៉ាងរបស់ព្រះអង្គ ដែលមានកន្លងមក ជាពិសេស កាលដែលធ្លាប់បានស្តាប់នូវឱវាទ និងដំបូន្មានរបស់ព្រះអង្គ ។ ការមិនបានជួបក្នុងរយៈកាលខ្លីតែប៉ុណ្ណោះ ស្រាប់តែពេលនេះ ព្រះអង្គបានស្ថិតនៅក្នុងមឈ្លូកញ្ចក់ លែងមានព្រះវាចាជាមួយនឹងយើងជាសិស្សគណទៅវិញ ។ ការទទួលអនិច្ចធម្ម **ព្រះធម្មវិបស្សនា សំ ប៊ុនធឿន កេតុធម្មោ** គឺជាការបាត់បង់ធនធានបញ្ញវន្តសង្ឃ ជាធម្មកោវិទមួយរូប ដែលក្នុងមួយជីវិតរបស់ព្រះអង្គបានលះបង់ និងបូជាព្រះកាយឧទ្ទិសចំពោះព្រះពុទ្ធសាសនា ដោយព្រះទ័យជ្រះថ្លាជាទីបំផុត ព្រមទាំងបានលះបង់កម្លាំងកាយ កម្លាំងចិត្ត និងកម្លាំងប្រាជ្ញា ដោយស្មោះក្នុងការបណ្តុះបណ្តាល ចែករំលែកនូវចំណេះដឹង ណែនាំកែលម្អសីលធម៌សង្គម មានព្រះព្រហ្មវិហារធម៌ ព្រមទាំងផ្តល់នូវភាពកក់ក្តៅ ដល់សិស្សគណទាំងអស់ស្ទើរតែគ្រប់មជ្ឈដ្ឋានទូទាំងប្រទេស ។ ពីមួយថ្ងៃទៅមួយថ្ងៃ ពីមួយខែទៅមួយខែ ពីមួយឆ្នាំទៅមួយឆ្នាំ ចេះតែវែងឆ្ងាយទៅៗ មានន័យថា **ព្រះធម្មវិបស្សនា សំ ប៊ុនធឿន**

**កេតុធម្មោ** បានឃ្លាតឆ្ងាយពីយើង ឬថាយើងទាំងអស់គ្នា ឃ្លាតឆ្ងាយពីព្រះអង្គជារៀងរហូត គ្មានពេល គ្មានថ្ងៃខែឆ្នាំណា នឹងបានជួបគ្នាទៀតឡើយ ។

អ្វីដែលនៅសេសសល់នោះ មានតែអនុស្សាវរីយ៍ ដែលព្រះអង្គធ្លាប់មានជាមួយយើង ពាក្យឱវាទប្រៀនប្រដៅបានដកជាប់នៅក្នុងហឫទ័យ ទីកន្លែងដែលព្រះអង្គធ្លាប់គង់នៅ និងព្រះវាចាដែលព្រះអង្គធ្លាប់មានសង្ឃដីកាជាមួយយើង ជាពិសេសស្រមោលអតីតកាលទាំងប៉ុន្មាន ដូចជាស្នាព្រះហស្ត និងសមិទ្ធិផលនានា ដែលព្រះអង្គបានកសាង នឹងមកពញ្ញាក់ នឹងដាស់នូវសោតិន្ទ្រិយារម្មណ៍ និងមនោរម្មណ៍របស់យើងទាំងអស់គ្នា ឲ្យនឹកហើយនឹកទៀត នឹកមិនភ្លេចនូវអ្វីដែលធ្លាប់មានតែប៉ុណ្ណោះ ។

ព្រះកាយរបស់ព្រះអង្គបានបាត់បង់ទៅក៏ពិតមែន ប៉ុន្តែអ្វីដែលនៅអមតៈសម្រាប់យើងទាំងអស់គ្នាចងចាំគឺៈ កេរ្តិ៍ឈ្មោះ កិត្តិនាម កិត្តិយស គុណធម៌ គុណវុឌ្ឍិ និងស្នាព្រះហស្តរបស់ព្រះអង្គ នៅតែមានជីវិតរស់រវើកជានិច្ច ។

សូមឲ្យឧត្តមវិរិយភាព របស់ព្រះអង្គ ដែលបានបូជា នឹងលើកស្ទួយព្រះពុទ្ធសាសនា និងសង្គមជាតិ ស្ថិតនៅរហូតក្នុងចិត្តគំនិតរបស់ប្រជាពលរដ្ឋខ្មែរ និងសិស្សគណគ្រប់រូប ដើម្បីបុព្វហេតុជាតិ សាសនា និងសុខដុមនីយកម្មសន្តិភាព វឌ្ឍនភាព សម្រាប់សង្គមជាតិទាំងមូលជារៀងរហូតតទៅ ។

ជាទីអវសាននេះ ខ្ញុំព្រះករុណា យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវគារវកិច្ច និងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅជាទីបំផុត ចំពោះព្រះវិញ្ញាណក្ខន្ធព្រះសព និងសូមឲ្យសេចក្តីប្រាថ្នាជាពុទ្ធភូមិរបស់ព្រះអង្គត្រូវបានសម្រេចតាមសេចក្តីប៉ងប្រាថ្នា កុំបីអាក់ខានឡើយ ។ មួយវិញទៀត សូមឧទ្ទិសមហាកុសលប្រគេនព្រះវិញ្ញាណក្ខន្ធព្រះធម្មវិបស្សនា **សំ ប៊ុនធឿន** កេតុធម្មោ បាននិមន្តទៅប្រតិស្ឋានក្នុងសុគតិភពសួគ៌ទេវលោក កុំបីអាក់ខានឡើយ ។ ដោយអំណាចនៃគុណធម៌នេះ សូមឲ្យសព្វសត្វទាំងឡាយទាំងពួងក្នុងលោក បញ្ចប់នូវពៀរវេរា នឹងគ្នា ឈប់ព្យាបាទគ្នា ចាប់ពីពេលនេះតទៅ និងសូមឲ្យលោកទាំងមូល បានទទួលបាននូវសុខដុមនីយកម្ម ជារៀងរហូតកុំបីអាក់ខានឡើយ !

**សូមអរព្រះរាជករុណាធិគុណ អរព្រះគុណ និងអរគុណ ! អនុមោទនា !**


អាសយដ្ឋានៈ ពុទ្ធមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅខាងលិចជើងភ្នំព្រះរាជទ្រព្យ ភូមិភ្នំ (ភ្នំអដ្ឋរស្ស) ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល ប្រទេសកម្ពុជា

ទំនាក់ទំនង : ០៨៦ ៨ ៧៧៧ ៩៣ / ០៩៧ ៩៨០ ៥២ ៨២ / ០៨៦ ២៨១ ២២៥

Venue: Vipassana Dhurak Buddhist Centre of Kingdom of Cambodia, Phnom village, Phsar Dek commune, Ponhea Leu district, Kandal province, Cambodia.

E-mail: vipassanadhurakphnomatharas@gmail.com

Contact us : 086 281 225 / 097 980 528 2 / 086 877 793


**សូមអរព្រះគុណ និងអរគុណ !**

Thank you beforehand!